និពន្ធដោយ ឧប សៅ សង្ហា

ថ្ងៃទី ២៤ មីនា ឆ្នាំ ២០១៥

**សាកល្បងពិចារណា**



# តើត្រូវបង្រួបបង្រួមខ្មែរតាមវធីណា ?

***"Tant qu'il y aura des dictatures, je n'aurai pas le cœur à critiquer une démocratie."***
Jean Rostand - Inquiétude d'un biologiste, 1967

«រហូតណា នៅតែមាន អំណាចផ្ដាច់ការ ខ្ញុំនៅតែគ្មានចិត្ត រិះគន់ លទ្ធិប្រជាធិបតេយ្យ»

# មាតិការឿង


សេចក្តីផ្តើម 1

មនោភាព - ១.ប្រយោជន៍រួមនិងប្រយោជន៍ជាតិ, ២. អំណាចប្រជាពលរដ្ឋ, ៣.បរិបទនៃស្រុកខ្មែរ 1

ទ្រឹស្តី និង វិធី - ១.ការរួបរួមជាតិ, ២.ការបង្រួបបង្រួមជាតិ 7

សេចក្តីនិដ្ឋាន 16

## សេចក្តីផ្តើម

លោក ម៉ម សូណង់ដូ ប្រធាន សមាគមន៍ អ្នកប្រជាធិបេតយ្យ លើកយក ប្រធានបទមួយមក ឲខ្មែរ ធ្វើការពិចារណា រួមគ្នា ដោយសួរជាសំណួរថា **តើយើងត្រូវបង្រួបបង្រួមខ្មែរតាមវិធីណា ?**

ជា **អង្គហេតុ**[1] ការរួបរួមខ្មែរ មានរួចស្រេចទៅហើយ ព្រោះខ្មែរ ជាប្រជាពលរដ្ឋ នៃ ប្រទេសមួយ ដែលមាន ឯកភាព ហើយ ខ្មែរម្នាក់ៗ ជា **ពលរដ្ឋ**[2] ត្រូវស្គាល់ ជា ដាច់ខាត នូវ សិទ្ធិ និង ករណីណកិច្ច របស់ខ្លួន ដែលមានចែងនៅក្នុងច្បាប់ជាតិ។ ដូច្នេះ បើយោងតាម អង្គហេតុ នេះ ការរួបរួម រវាងខ្មែរ នឹង ខ្មែរ វា មាន លក្ខណ: ជា **ក្រិត្យ**[3] នៅក្នុងគ្រោង សិទ្ធិ និង ករណីណកិច្ច នៃ ប្រជាពលរដ្ឋ នោះឯង។

ជា ក្រិត្យ ព្រោះ ពលរដ្ឋម្នាក់ៗ មាន សេរីភាព ពេញលេញ ដែលមាន ច្បាប់ «**សេរីភាពសាធារណ:**»ជា អ្នកធានា។ ដូច្នេះ សេរីភាព ជា សិទ្ធិ ឯចំណែក សេរីភាពសាធារន: វិញ ជា ច្បាប់ ព្រោះ ប្រើសេរីភាព នៅ កន្លែងសាធារណ: ឥតមានច្បាប់សំរាប់គ្រោងសេរីភាព គឺនាំបង្កើត អនាធិបេតយ្យ។ តែបើ ប្រើច្បាប់ សេរីភាពសាធារណ: សំរាប់ បង្ក្រាប សេរីភាព នៃ ការបញ្ចេញមតិ នៃ ការប្រជុំ ឬ ការផ្តុំគ្នា ជាសាធារណ: ដែលមានចែង នៅក្នុង រដ្ឋធម្មនុញ្ញ គឺជា អំណាចផ្តាច់ការ។ នៅក្នុងចំណុច នេះ វា មាន ទំនាក់ទំនង ទៅនឹង ការរួបរួមខ្មែរ ដែលមាន ករណីយកិច្ច ជា មូលដ្ឋាន ហើយនឹង ការបង្រួបបង្រួមខ្មែរ ដែលមាន ជា សិទ្ធិ ជា គ្រិះ។ ជា ករណីណកិច្ចព្រោះខ្មែរ ត្រូវតែរួបរួមគ្នា ក្នុងឋានៈ ជា ពលរដ្ឋ ; ជា សិទ្ធិ ព្រោះ នៅក្នុង ការបង្រួបបង្រួម មិនមាន លក្ខណ: ជា ការបង្ខំ ទុកសិទ្ធិ ឲពលរដ្ឋម្នាក់ មានសេរីភាព ក្នុងជម្រើស នៃការចូលរួម។ តែបើមាន ការបង្ខំ គឺ អំណាចផ្តាច់ការ។ នៅក្នុង បញ្ហា ប្រើសិទ្ធិ ក្នុង គ្រោង ការបង្រួបបង្រួម នេះ ដែល លោក ម៉ម សូណង់ដូ លោក លើកមកចោទ ជា សំណួរ ថា ត្រូវធ្វើតាមវិធីណា។

## មនោភាព[4]

ប្រើសិទ្ធិ ព្រោះ ការបង្រួបបង្រួម វាមាន អ្នកបង្រួបបង្រួម ហើយនិង គោលដៅ របស់វា។ ដូច្នេះ ការបង្រួបប្រួម វាមាន អត្ថរស នៃ ប្រយោជន៍ របស់ ក្រុម ពួក បក្ស និមួយៗ ដែលគេមាន គោលដៅ របស់គេ មានវប្បធម៌ ក្រុម ឬ បក្ស។ ក្នុងចំណុចនេះ លោក ម៉ម សូណង់ដូ លោកបាន ឆ្លើយរួចហើយ នឹងសំណួរ របស់គាត់ គឺ វិធី ដែលអាចធ្វើទៅបាន គឺត្រូវ ទុក ជាតិ ជា ធំបើនិយាយឲខ្លី គឺ ទុកប្រយោជន៍ជាតិ ជាគោលៈ **បង្រួបបង្រួម ជុំវិញ ខ្លឹមជាតិ**។ មួយវិញទៀត លោក បន្ថែមថា អ្នកបង្រួបបង្រួម ឬ អ្នកនយោបាយ ត្រូវមាន សីលធម៌ ខ្ពង់ខ្ពស់ ជាគំរូដល់ ប្រជាពលរដ្ឋ។ កត្តា ទាំងពីរ នេះ ដែល លោក ទុក ជា ល័ក្ខខ័ណ្ឌ នៃ ជោគជ័យ នៃ ការបង្រួបប

---

[1] អង្គហេតុ= Fact។

[2] ពលរដ្ឋ= ជនមានសិទ្ធ មានករណីយកិច្ច ; Citizen។

[3] ក្រិត្យ= កាតព្វកិច្ច ជាសីលធម៌ ; Moral obligation។

[4] មនោភាគ= គំនិតទូទៅ ; Concept។

ជ្រួម។ សួរថា តើនៅមានអ្វីខ្វះខាតទៀត ក្នុង ចម្លើយ របស់ លោក ម៉ម សូណង់ដូ ? ដូចជាគ្មាន ទេ ; តែក៏ ជា ចម្លើយ ជា ទូទៅដែរ មានភាព សមញ្ញ ស្រួលយល់ តែក្នុងនោះ នៅមានបញ្ហា ជាច្រើនទៀត ដែលត្រូវ បង្ហាញបំភ្លឺ បន្ថែម ដើម្បី អះអាងការពិត នៃ ចម្លើយ ជា ពិសេសនៅក្នុង **បរិបទ**[5] ខ្មែរ។

តាមស្នាម ប្រវត្តិសាស្ត្រ ប្រជាជាតិខ្មែរ កើតឡើង ពីអំណាច វណ្ណៈអ្នកដឹកនាំ ហើយ ការវិវត្តន៍ មានដំណើរ តិចតួចណាស់ រហូតអាចចាត់ទុកថា ស្ថិននៅក្នុងភាពនឹងថ្កល់ ជាពិសេសនៅក្នុង វិស័យ សេរីភាព នៃ ប្រជារាស្ត្រ ដែលនាំឲអ្នកដឹកនាំ ប្រើអំណាច ដើម្បីរក្សា បុព្វសិទ្ធិ ជាមរតក របស់គេ។ នៅក្នុង **បដិក្ខិត**[6] របស់ អ្នកដឹកនាំ នេះ នាំឲ ពួកនេះ ទុកប្រយោជន៍ជាតិ ជា កម្មសិទ្ធិ របស់ខ្លួន។ ឯចំណែក ប្រជារាស្ត្រ វិញ ទុកផលដែលខ្លួន បានទទួល ឬ រកបាន ជា អំណោយ របស់ អ្នកដឹកនាំ ដែលគេចែកអោយ តាមប្រយោជន៍ របស់គេ។ ដូច្នេះ អ្នកដឹកនាំ រស់ក្នុងទំលាប់ ជា ម្ចាស់ រីឯ ប្រជាពលរដ្ឋ រស់ នៅក្នុងទំលាប់ ជា អ្នករង់ចាំការជួយឧបត្ថម្ភ។ តែ ការហួសទៀត ធ្វើនៅក្នុងប្រយោជន៍ អ្នកដឹកនាំ ជានិច្ច។ សួរថា ក្នុងគំនិត បង្រួបបង្រួម ជាតិ ដោយយកប្រយោជន៍ជាតិ ជា គោលដៅ តើ នរណា ត្រូវដូរ **មានសិកភាព**[7] ? អ្នកដឹកនាំ ជាតិ ឬ ប្រជារាស្ត្រ ?

ប្រជាពលរដ្ឋខ្មែរ សព្វថ្ងៃនេះ មាន **ភោគប្រយោជន៍**[8] មួយសំខាន់ណាស់ ដោយឥតដឹងខ្លួន គឺ គាត់ ជា អ្នកបោះឆ្នោត ក្នុងគ្រោងលទ្ធិប្រជាធិបតេយ្យ ទោះបី ជា **មជ្ឈិមប្រជាធិបតេយ្យ**[9] បែបកុម្មុយនិស្ត កែលំអ សំរាប់ បំភាន់ ដែលយើងឲឈ្មោះវាថា ជា **ប្រជាធិបេតយ្យអាស្រ័យបក្ស** យកការបោះឆ្នោត ជា មធ្យោបាយ សំរាប់ការពារ អំណាចផ្តាច់ការ ឬ ប្រយោជន៍របស់សម្ពន្ធមិត្រ នៃ គណបក្សនយោបាយ ដូចសព្វថ្ងៃ គណបក្សប្រជាជន និង គណបក្សសង្គ្រោះជាតិ គេនាំគ្នាចុះសម្រុង ធ្វើកំណែទម្រង់ ច្បាប់បោះឆ្នោត ដើម្បីរក្សាប្រយោជន៍ និងអំណាច នៅ អាណត្តិ ទី៦។

ការបោះឆ្នោត ក្នុងគ្រោង ប្រជាធិបតេយ្យបក្ស នេះ មានតាំង ពីឆ្នាំ ១៩៩៣ រហូតមកដល់ ឆ្នាំ ២០១៣ គឺថា គណបក្សនយោបាយ ដែលបានជាប់ឆ្នោត មិនដែលគោរព ឆន្ទៈប្រជាពលរដ្ឋ យកចំណង់ របស់ ប្រជាពលរដ្ឋ ទៅកែឆ្នៃ តាមការ ព្រមព្រៀងគ្នា ដើម្បី រកប្រយោជន៍សំរាប់ខ្លួនឯងជានិច្ច។ តែទម្លាប់នេះ ហាក់បីដូច ជា ប្រជាពលរដ្ឋ មិនយកមកទុក ជា បទពិសោធ ទាល់តែសោះ។ បើមិនយកមកធ្វើ ជាបទពិសោធ អាចមានន័យថា គាត់មិនយកវា មក ពិចារណា អំពី ផលវិបាក ដែលគាត់ទទួល ផ្ទាល់ខ្លួន រស់ក្នុង ទុក៌តភាព ជាអ្នករងគ្រោះ នាំឲជាតិ ទទួល រងគ្រោះ ដូចត្រូវ អំពើរ ដូច្នេះឯង។ ពីរ ទស្សវត្សរ៍ (២០ ឆ្នាំ) នាំគ្នា ទៅបោះឆ្នោត ៥ ដង ហើយក៏បានទទួលទុក ៥ជាន់ដែរ រហូតក្លាយខ្លួន ទៅជា អនុប្រជាជន នៅក្នុងស្រុកខ្លួនឯង តែហាក់បី នាំគ្នា អង្គុយ ចាំបោះឆ្នោត លើកទី៦ ម្តងទៀត ទោះបីមានសង្ឃឹម តិចតួច យ៉ាំងណាក៏ដោយ ថាអាណត្តិ ទី៦ ក៏មិនប្រាកដ នាំឲខ្លួន មានជីវភាពប្រសើរឡើងដែរ។

---

[5] បរិបទ= បរិការណ៍ ; Context។
[6] បដិក្ខិត= ធ្វើដោយឥតដឹងខ្លួន ; Reflex។
[7] មានសិកភាព= ចិត្តគំនិត ; Mentality។
[8] ភោគប្រយោជន៍= Asset, Trump។ Atout។
[9] មជ្ឈឹមប្រជាធិបតេយ្យ= Centralism democratic : ជាលទ្ធិប្រជាធិបតេយ្យ បែបពួកកុម្មុយនិស្ត។

គឺ សុខចិត្ត នាំគ្នារស់មួយគែ គឺថា ស៊ីថ្ងៃ អត់ល្ងាច ស៊ីល្ងាច អត់ថ្ងៃ បើឈឺ ដេកចាំស្លាប់។ ពាក្យ **រស់មួយគែ** វាមាន លក្ខណៈ ជា អាត្មានិយម។ តើ ជា កំហុស នរណា ? អ្នកដឹកនាំជាតិ ?

អ្នកដឹកនាំជាតិខ្មែរ គ្រប់ស្រទាប់ ហើយនិង អ្នកនយោបាយជាអាជិព រស់នៅក្នុង ឬ ជុំវិញ ប្រព័ន្ធនយោបាយសព្វថ្ងៃ មិនអាច បោះបង់ប្រយោជន៍គាត់ចោលបានជាដាច់ខាត ព្រោះ គតិ ហើយនឹង កាយរបស់ពួកគាត់ វា **ភ្នោក**[10] នឹងវប្បធម៌ ពុករលួយ **និទ្ទណ្ឌ**[11] ភូតកុហក ហើយ នឹង ការមិនទទួលខុសត្រូវ ដែលនាំ ឲគាត់ ក្លាយជា មនុស្ស ខ្វាក់ នៅចុះពោះមុខ ទុក្ខវេទនា របស់ ប្រជាពលរដ្ឋ ហើយនឹង គ្រោះថ្នាក់ជាតិ។ ចិត្តគំនិត ហ្នឹង មិនមែន ជា ការគិតស្មាន តែ ជា អង្គហេតុ មាន លទ្ធផលចង្រៃដល់ប្រជាជាតិ ជា ភស្តុតាង។ ហើយ អង្គហេតុ នេះ ជា **អង្គហេតុជាប់លាប់**[12] ក្លាយជាទំលាប់ នៅក្នុងសង្គម។ សួរថា តើយើង នៅមាន សង្ឃឹម ឬ ជំនឿ ថា វណ្ណៈ ហ្នឹង អាចដូរ ដោយខ្លួនឯង ពី អកុសល ទៅ កុសល បានដែរឬទេ ?

ពិតប្រាកដ ណាស់ ថា អង្គហេតុ ហ្នឹង ជា កំហុស របស់ អ្នកប្រព្រឹត្តិ។ តែសួរជាសំណួរថា តើនរណា ជា អ្នកវិនិច្ឆ័យ ? បើ អាជ្ញាធរ ក៏ជាក្រុមតែមួយ ជាដៃជើង របស់ អ្នកប្រព្រឹត្ត។ ដូច្នេះ នាំគ្នា ដេកចាំ ចោរលួចតាមចិត្ត ឥតមានទោស ហើយសង្ឃឹមថាវានឹងដូរចិត្ត គឺដូចជានាំគ្នា ដេកចាំ ផ្លែល្វា ប្រែក្លាយជា ស្វាយ។ ដូច្នេះ តើត្រូវធ្វើវិធីណា អាចឲមានបំលាស់ប្តូរ ?

សំណួរ ហ្នឹង វាជា កូនសំណួរ នៅក្នុង ប្រធានបទ ដែលសន្មត់ ថា **រួបរួមគ្នា** វាជា ចម្លើយគ្រប់គ្រាន់ សំរាប់ដោះស្រាយ នូវ បញ្ហា ដែលប្រជាជាតិជួបប្រទះ។ ដូចបាន ជំរាបខាងលើរួចមក ហើយ ថា ការរួបរួម វាមានរួចស្រេច ក្នុង ធាតុ ពលរដ្ឋ **ចុះនាម**[13] ក្នុងគ្រោង សិទ្ធិ ហើយ នឹង ករណីយកិច្ច។ តែ ពលរដ្ឋ ជា មនុស្សលោក ហើយ ប្រជាជាតិ ជា សង្គមនយោបាយ។ អត្ថរស នៃ មនុស្សលោក គឺ ចំណង់គ្មានកំរិត រីឯ អត្ថរស នៃ សង្គមនយោបាយ គឺ សង្គម មានការរៀបចំ ដើម្បីធ្វើ ឬ ការពារអ្វីមួយ។ សង្គមមានការរៀបចំ គឺ គ្រប់គ្រោង ចំណង់គ្មានកំរិតដែល ជា សេរីភាព នៃ មនុស្សលោកឲមានសណ្តាប់ធ្នាប់។ **ការទំនាក់ទំនង រវាង សេរីភាព ជាមួយនឹង សណ្តាប់ធ្នាប់ នេះឯង** ដែលមាននៅក្នុង សំណួរ របស់ ប្រធានបទ គឺថា តើត្រូវបង្រួបបង្រួមខ្មែរតាមវិធីណា ?

ចំណង់គ្មានកំរិត របស់ មនុស្សលោក វាឆ្លើយនឹង សេចក្តីត្រូវការ ៥យ៉ាង របស់ មនុស្សលោកៈ

សេចក្តីត្រូវការ នៃ ជីវសាស្ត្រ (អាហារទទួលទាន) ; សេចក្តីត្រូវការ នៃ សវត្ថភាព (ជម្រង ហើយនឹង សន្តិសុខ) ; សេចក្តីត្រូវការ នៃ សមាជិកភាព (រស់នៅក្នុងក្រុមមួយ) ; សេចក្តីត្រូវការ នៃ ការរាប់អាន ពីអ្នកដ៏ទៃ (ការកោតសរសើរ) និង សេចក្តីត្រូវការ នៃ ការបង្កើត ស្នាដៃអ្វីមួយ ដោយខ្លួនឯង[14]។

សេចក្តីត្រូវការ ទាំងឡាយ ហ្នឹង វាមាន លំដាប់ ពីទី១ ដល់ ទី៥ ជូនកាលអាចលោតផ្លោះដំណាក់បានខ្លះ ទៅតាម លទ្ធភាព របស់មនុស្សម្នាក់ៗ។ សេចក្តីត្រូវការទាំងនេះ គឺជាចំណង់គ្មានកំរិត

---

[10] ភ្នោក= Impregnate។
[11] និទ្ទណ្ឌ= ការគ្មានទោស ; Impunity។
[12] អង្គហេតុជាប់លាប់= Makes lasting។
[13] ចុះនាម= Inscribe (F. S’inscrire) ។
[14] The five needs of Maslow។

របស់ មនុស្សលោករស់នៅក្នុងសង្គម ស្វែងរក សុភមង្គល ក្នុងជម្មជាតិ ជា មនុស្សលោក។ តែនៅក្នុងសង្គមជាតិ មានបែងចែក ជាពីរប្រយោជន៍ ដែលពលរដ្ឋម្នាក់ៗត្រូវស្គាល់ច្បាស់, ចេះញែក ដើម្បីកុំឲមានការភាន់ច្រឡំ។ ប្រយោជន៍ទាំងពីរមានៈ

## ១. ប្រយោជន៍រួម នឹង ប្រយោជន៍ជាតិ

សង្គមមនុស្សលោក ជា សង្គមនយោបាយ មានគោលដៅសំខាន់ពីរ គឺ គ្រប់គ្រង ប្រយោជន៍រួម ហើយនឹង ប្រយោជន៍ជាតិ។ ប្រយោជន៍រួម ជា ប្រយោជន៍បុគ្គល **គ្រោង**[15]ដោយច្បាប់។ រីឯ ប្រយោជន៍ជាតិ វិញ ជា **ប្រយោជន៍សាធារណៈ** អ្វី សំរាប់ បំរើ ប្រជាពលរដ្ឋ ជា ប្រយោជន៍ជាតិ ហេតុដូច្នេះឯងហើយ បានជា ប្រជាពលរដ្ឋ ការពារប្រយោជន៍ជាតិ ព្រោះវាជា ប្រយោជន៍ របស់ខ្លួនផ្ទាល់, ឧបមា បើ ប្រជាពលរដ្ឋ រលាយ គឺ ជាតិ រលំ ហើយ វាត្រឡប់ **ទៅវិញទៅមក**[16] ដូច្នេះ ប្រយោជន៍រួម ហើយនឹង ប្រយោជន៍ជាតិ ជាប្រយោជន៍តែមួយ តែគ្រប់គ្រងដោយច្បាប់ពីរខុសគ្នា ទី១ ក្នុងគ្រោងច្បាប់ សេរីភាពសាធារណៈ ; ទី២ ក្នុងគ្រោងច្បាប់ ព្រហ្មទណ្ឌ តែច្បាប់ទាំងពីរនេះ ស្ថិតនៅក្រោមច្បាប់ រដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល ធានា សេរីភាព របស់ ប្រជាជន។

យើងអាច ឆ្លើយ ជាសំណើរ ថា ការបង្រួបបង្រួមខ្មែរ គឺ បង្រួបបង្រួម នៅជុំវិញ ប្រយោជន៍ របស់ ប្រជាពលរដ្ឋ ដែលជា **លទ្ធផលនៃអំពើរួម**[17] រវាង ប្រយោជន៍រួម ជាមួយនឹង ប្រយោជន៍ជាតិ។ តើត្រូវធ្វើតាមវិធីណា ?

ជាបឋម ប្រជាពលរដ្ឋ ត្រូវមានចំណង់ រក ប្រយោជន៍រួម និង ប្រយោជន៍ជាតិ ក្នុងឋានៈខ្លួន ជា មនុស្សលោកផង ជាពលរដ្ឋផង។ ចំណង់នេះឯង ជាការលើកទឹកចិត្តទីមួយ ដែលត្រូវមានចាំបាច់។ បន្ទាប់មក ត្រូវមានការប្តេជ្ញាចិត្ត ថា ត្រូវតែធ្វើឲបានសំរេច រួចហើយ ត្រូវជ្រើសរើស វិធី ដែលត្រូវធ្វើ តាម មធ្យោបាយ ដែលពលរដ្ឋម្នាក់ៗមាន បូកគ្នាជាមធ្យោបាយរួម ហើយនឹង មធ្យោបាយជាតិ។

មធ្យោបាយពលរដ្ឋ គឺប្រើ សិទ្ធិ នឹង ករណីយកិច្ច ជាពលរដ្ឋ ; មធ្យោបាយរួម គឺប្រើអំណាច អហឹង្សា ជាប្រជាពលរដ្ឋ ; មធ្យោបាយជាតិ គឺប្រើច្បាប់ជាតិ ហើយនឹង អន្តរជាតិ ជាអាវុធ។

**ករណីយកិច្ច ៖** គឺត្រូវមាន កាតព្វកិច្ច ចូលរួម ក្នុងកិច្ចការសាធារណៈ ហើយនិង កិច្ចការនយោបាយ ស្គាល់ដឹងច្បាស់ អំពី សិទ្ធិ របស់ខ្លួន អំពី ករណីយកិច្ច របស់ អ្នកដឹកនាំ អំពី ប្រយោជន៍ខ្លួន ប្រយោជន៍រួម ហើយនឹង ប្រយោជន៍ជាតិ។ ជាសង្ខេប ករណីយកិច្ច គឺការចេះដឹង ដែលពលរដ្ឋ ត្រូវមាន ដើម្បី អាចឲខ្លួន អាចមានលទ្ធភាពវិនិច្ឆ័យ លើ សកម្មភាព ស្ថាប័នជាតិ,អំពើរបស់អ្នកដឹកនាំជាតិ នឹង អ្នកនយោបាយ។

**សិទ្ធិ ៖** គឺ ហ៊ាន តវ៉ា ឬ ប្រឆាំងនឹង អំពើ អយុត្តិធម៌ អសីលធម៌ ហើយនឹង អំពើក្បត់ជាតិ។ សិទ្ធិ ជា សេរីភាព នៃជម្រើស រវាង ការចូលរួម ពហិការ ឬ ការបដិសេធ ក្នុង សកម្មភាពសាធារណៈ

[15] គ្រោង= Frame។
[16] ទៅវិញទៅមក= Vice-Versa។
[17] លទ្ធផលនៃអំពើរួម= Resultant។

សកម្មភាពនយោបាយ ដូចយ៉ាង ការបោះឆ្នោតជាតិ ឬ បាតុកម្ម។ ពហិការ ជាសកម្មភាពអហិង្សា ប្រឆាំងនឹង អំពើអ្វីមួយ រីឯ ការបដិសេធ ជាការតបតនឹង និគ្រោះ ការបង្ខំដោយប្រើកម្លាំង ពីសំណាក់ អ្នកមានអាវុធ។ **ជាតក្កលោម**[18] នៅចំពោះមុខ និគ្រោះ បែបនេះ តែងតែ មានកើត អំពើហឹង្សាជានិច្ច ដូច្នេះ ការប្រើសិទ្ធិ តបត ជាប្រតិកម្ម ទុកជា អំពើ ការពារខ្លួន តែប៉ុណ្ណោះ ; ឧបមា ឈរឲគេវៃ ឬ បាញ់សម្លាប់ គ្មានប្រតិកម្ម មិនមែន ជាមនុស្សលោកទេ។ សិទ្ធក៏ជា ករណីយកិច្ចដែរ ព្រោះពលរដ្ឋម្នាក់ៗ ត្រូវដឹងឲច្បាស់ អំពី សិទ្ធិខ្លួន ជាបុគ្គល ជាពលរដ្ឋ ជាប្រជាពលរដ្ឋ នឹង ជាអធិបតីខ្លួន ដែលជា ម្ចាស់នៃអំណាចរដ្ឋ។

## ២. អំណាចប្រជាពលរដ្ឋ

អំណាចរដ្ឋ ជាឧបករណ៍ នៃ **អំណាចប្រជាពលរដ្ឋ** ដែលជាអំណាចរដ្ឋធម្មនុញ្ញ ព្រោះវា មានកំណើត ពីរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល របស់ជាតិ។ អ្វីដែល អាជ្ញាធរ ឬ រដ្ឋប្រតិបត្តិ គឺធ្វើក្នុងនាម ប្រជាពលរដ្ឋ សំរាប់ប្រជាពលរដ្ឋ។ ហេតុ ជារូបិភាព ច្បាស់លាស់ នៃអំណាចប្រជាពលរដ្ឋ ដូច្នេះអំណាចណាមួយ ធ្វើនិគ្រោះ មកលើប្រជាពលរដ្ឋ ជាអំណាចផ្តាច់ការខុសច្បាប់ជាតិ។ ប្រជាពលរដ្ឋ ប្រើអំណាចខ្លួន ប្រឆាំងនឹង អំណាចផ្តាច់ការ ជា **អំពើស្របច្បាប់**នឹង ជា **អំពើធម្មានុរូប**។ អំពើស្របច្បាប់ ព្រោះអំណាចប្រជាពលរដ្ឋ មានអត្ថរស ជាច្បាប់ ; អំពើធម្មានុរូប ព្រោះជាសិទ្ធិ របស់ប្រជាពលរដ្ឋ ក្នុងឋានៈខ្លួន ជាម្ចាស់នៃអំណាច។ ប្រើអំណាចរដ្ឋ ត្រូវចាំបាច់ **អនុលោម**[19]នឹង លក្ខណៈពីរយ៉ាង **ស្របច្បាប់**[20] នឹង **ធម្មានុរូប**[21]។ ប្រព្រឹត្តតាមច្បាប់វាពិតជាមានលក្ខណៈ ស្របច្បាប់ តែប្រព្រឹត្ត អំពើ ហឹង្សា ទៅលើប្រជាជន ក្នុងករណីយកិច្ចនេះ អាជ្ញាធរ គ្មានធម្មានុរូប ព្រោះខ្លួន គ្មានសិទ្ធិប្រើអំណាច ធ្វើនិគ្រោះ ទៅលើម្ចាស់អំណាចបាននោះឡើយ។ ដូចថ្មីៗនេះ លោក ហ៊ុន-សែន ថ្លែងថា បើនរណាមួយ ប្រើអំណាចប្រជាពលរដ្ឋលោក នឹងយកអាវុធ ទៅបង្ក្រាប។ សេចក្តីប្រមាទនេះ គ្មានគ្រឹះច្បាប់ នឹង គ្មានការប្រកដនិយមទេ ព្រោះ អាវុធ ជាឧបករណ៍ របស់អំណាចប្រជាពលរដ្ឋ មិនអាចនរណាម្នាក់ យកវា ទៅប្រើ ដោយគ្មានការអនុញ្ញាតិពីប្រជាពលរដ្ឋបាននោះឡើយ។

បើយោងលើ លទ្ធិប្រជាធិបតេយ្យ ការប្រើអំណាចប្រជាពលរដ្ឋ ដោយប្រជាពលរដ្ឋ ជាការប្រើច្បាប់ ហើយនឹង សិទ្ធិ ជាម្ចាស់អំណាចតែប៉ុណ្ណោះ។ សួរថា **តើត្រូវប្រើតាមវិធីណា ?** នៅក្នុងប្រទេស មានលទ្ធិប្រជាធិបតេយ្យ ពិតប្រាកដ ចម្លើយនឹងសំណួរនេះ វាមាន ចែងនៅក្នុងច្បាប់ជាតិ ហើយ មាននៅក្នុង ទំលាប់ ជាធម្មតា របស់បុគ្គលម្នាក់។ សិទ្ធិបោះឆ្នោត នៃពលរដ្ឋ ជាការប្រើអំណាចប្រជាពលរដ្ឋ ហើយបន្ទាប់ពី បោះឆ្នោតរួច អាជ្ញាធរ ដែលជា **អំណាចសីទ្ធិរដ្ឋ**[22] ចែងនៅក្នុងអំណាច នីតិប្រតិបត្តិ ដែលមាន រដ្ឋាភិបាល ជាអ្នកគ្រប់គ្រង យក អំណាចប្រជាពលរដ្ឋមកកាន់កាប់ នៅក្នុងអាណត្តិ **អង្គនីតិបញ្ញត្តិ**[23] ដែលមាន គណបក្សភាគច្រើន, តំណាង ប្រជា

[18] ជាតក្កលោម= សមហេតុផល ; Logically។

[19] អនុលោម= សម្រប ; Conform។

[20] ស្របច្បាប់= Legal។

[21] ធម្មានុរូប= Legitimate។

[22] អំណាចសិទ្ធិរដ្ឋ= អំណាចអធិបតេយ្យ។

[23] អង្គនីតិបញ្ញត្តិ= អាណត្តិរបស់រដ្ឋសភា ; Legislative។

ពលរដ្ឋ, ជាអ្នកផ្ដល់ អំណាចដឹកនាំជាតិ ដល់ រដ្ឋាភិបាល។ តែថា អំណាចប្រជាពលរដ្ឋ ដែល អំណាចនីតិបញ្ញត្តិ នឹងអំណាចនីតិប្រតិបត្តិ យកមកប្រតិបត្តិគឺគ្រាន់តែឋិននៅក្នុង**គ្រោង**[24] អំណាចផ្ទេរ តែប៉ុណ្ណោះ។ ក្នុងអំណាចផ្ទេរ នេះ បញ្ជាក់ថា ម្ចាស់នៃអំណាច គឺ ប្រជាពលរដ្ឋមាន សិទ្ធិ គ្រប់បែបយ៉ាង គ្រប់ពេលវេលា តាមពិនិត្យលើសកម្មភាព របស់អំណាចនីតិបញ្ញត្តិ នឹងអំណាចនីតិប្រតិបត្តិ។ នៅក្នុងល័ក្ខខ័ណ្ឌនេះហើយ ដែលប្រជាពលរដ្ឋ ប្រើអំណាចរបស់ខ្លួន ដែលមានចែងនៅក្នុងលទ្ធិប្រជាធិបតេយ្យមានឈ្មោះថា«**ប្រជាធិបតេយ្យតំណាង**[25]»។

## ៣. បរិបទ នៃស្រុកខ្មែរ

តែនៅក្នុង **បរិបទ**[26] ស្រុកខ្មែរ ដែលអនុវត្តិ លទ្ធិប្រជាធិបតេយ្យ អាស្រ័យបក្ស ដែលជាលទ្ធិ បែបកុម្មុយនិស្ដ យកការបោះឆ្នោត ជាឡប់ឡែ ប្រែរូប អំណាចប្រជាពលរដ្ឋ ឲទៅជាស្រមោល របស់អំណាចផ្ដាច់ការ ដែលជា ឧបសគ្គ នូវដំណើររលូន[27] នៃលទ្ធិប្រជាធិបេតយ្យ ដូច្នេះ ប្រជាពលរដ្ឋត្រូវប្រើអំណាចខ្លួន បែប តស៊ូមតិ មានរូបភាព ជាមហាបាតុកម្ម ជា**សយម្ភូត**[28] ដូចធ្លាប់កើតមានក្នុងឆ្នាំ ២០១៣។ គេអាច ឆ្លើយតបវិញថា ២០១៣ ជាបរាជ័យ ដូច្នេះដើរតាមស្នាមបែបនេះ វាគ្មានប្រសិទ្ធអ្វីនេះឡើយ។ ទង្វើ ក្នុងឆ្នាំ ២០១៣ ជា បរាជ័យពិត តែជា បរាជ័យ របស់អ្នកដឹកនាំគណបក្សសង្គ្រោះជាតិ តែប៉ុណ្ណោះ ព្រោះអ្នកទាំងនោះ យកការបោកប្រាស់ ប្រជាពលរដ្ឋ ជាយុទ្ធសាស្ត្រ រកប្រយោជន៍ ដែលនាំមិនបានសម្រេច នៃគោលបំណង។ ការចាញ់បោក ជាការផ្លាត់ តែមិនមែនជាបរាជ័យ របស់ របៀបប្រើអំណាច ប្រជាពលរដ្ឋ ដោយប្រជាពលរដ្ឋ តាមរបៀបមហាបាតុកម្មនោះទេ។ ជា ការប្រើរបៀបល្អមួយ វាគ្រាន់តែខ្វះអ្នកដឹកនាំ មាន **សម្មាគំនិត**[29] មាន **ពលវសទ្ធា**[30] នឹងមាន **ថាមពល**។ តែការរកឃើញ ដោយប្រជាពលរដ្ឋ នូវអ្នកដឹកនាំបែបនេះឃើញ លុះត្រាតែពលរដ្ឋម្នាក់ៗ មានវត្ថុធាតុទាំងបីយ៉ាងនេះ នៅក្នុងសន្ដានចិត្ត ខ្លួនឯងដែរ។ ដូច្នេះ វត្ថុបីយ៉ាងនេះ ជាកម្លាំងផង ជាកត្តា នៃការបង្រួបបង្រួម នៃប្រជាពលរដ្ឋ។ ការផុសឡើងនៃវត្ថុបីយ៉ាងនេះ ក្នុងសន្ដានចិត្ត របស់ខ្មែរម្នាក់ៗ ជាការចាំបាច់ នូវជោគជ័យ នៃការបង្រួបបង្រួមខ្មែរ ដើម្បីកសាងជាតិ នៅក្នុងប្រយោជន៍រួម នឹង ប្រយោជន៍ជាតិ។

គ្មានអ្វីដែលអាចកើតឡើងបាន ដោយគ្មានចំណង់ចង់បាន ហើយនឹង ការតស៊ូនោះឡើយ។ អ្វីដែលកើតឡើងពី ការចែដន្យ អាចទុកជាសំណាង ក៏បាន ក៏អាចទុកជា អន្ដរាយ នោះដែរ។ ជាសំណាង លុះត្រាការកើតឡើងនោះ បានដល់ មនុស្សល្អ មានប្រជ្ញា អាចចេះឆ្នៃសំណាង ឲទៅជាសម្បត្តិធម៌បាន។ ជាអន្ដរាយ នៅក្នុងករណីយណា ដែលសំណាងកើតពីការចៃដន្យនេះ បាន

[24] គ្រោង= Cadre។

[25] ប្រជាធិបតេយ្យ តំណាង= Representative democracy ; Démocratie représentative។

[26] បរិបទ= បរិការណ៏ ; Context។

[27] ដំណើររលូន= Good working ; bon fonctionnement។

[28] សយម្ភូត= ដែលធ្វើដោយឯងឯង ; Spontaneous, Spontané។

[29] សម្មាគំនិត= គំនិតត្រូវ ; Just idea, Idée juste,

[30] ពលវសទ្ធ= សេចក្ដីក្លៀវក្លា ; passion។

ដល់ **កុសីតបុគ្គល**[31] បុគ្គលទុច្ចរិត ប្រើសំណាង ក្នុងការខ្ជិលច្រអូស ឬ មានតណ្ហា ប្រើដើម្បីបំផ្លាញអ្នកដ៏ទៃ ដូចករណីយ អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ ឆ្លៀតយក ចលនាប្រជាពលរដ្ឋ ផុសចេញ ដើម្បីប្រឆាំងនឹង អយុត្តិធម៌ ដែលជាអាណាប្រយោជន៍ សំរាប់ជាតិ មកបំផ្លាញជាតិខ្លួនឯង។ ក៏ដូចករណីយ ពួកខ្មែរក្រហាម ទទួលបានជោគជ័យ ដោយចៃដន្យ យកសំណាងនេះ មកធ្វើជាកម្លាំងហឹង្សា ដែលពុំអាចខ្មែរណាស្រមៃឃើញបាន មកប្រើ សម្លាប់ប្រជាពលរដ្ឋខ្លួនឯង ផ្ទុយពីអ្នកដឹកនាំយួន ឆ្លៀតយក ទុព្វលភាពខ្មែរ មកឆ្នៃជា លាភជ័យ សំរាប់ សមិទ្ធិ មហិច្ឆតាជាប្រវត្តិសាស្ត្រ របស់គេ គឺបង្កើត **មហាវៀតណាម** ដែលជាតណ្ហួចិនថ្មី។

## ទ្រឹស្តី និង វិធី

តើត្រូវបង្រួបបង្រួមខ្មែរ តាមវិធីណា ? គួរសួរ ជាបឋម នូវសំណួរថា តើខ្មែរត្រូវរួបរួមគ្នាតាមវិធីណា ? ព្រោះថាពាក្យ បង្រួបបង្រួម ត្រូវមាន អ្នកបង្រួបបង្រួម តែថា អ្នកបង្រួបបង្រួមខ្មែរ វាមិនអាចមានកើត បើខ្មែរ មិនទាន់មានការរួបរួមគ្នានៅឡើយ ព្រោះការរួបរួម គឺដូចជា លក្ខខណ្ឌ **ដីដែលមានជីជាតិ** រីឯ ការបង្រួបបង្រួម វិញ គឺដូចជា អំពើ **ដាំបន្លែក្នុងចំការ**។ មួយជា **បុរេលក្ខខណ្ឌ**[32] មួយជា **របៀបរៀបចំ**។ ដូចបានជំរាបខាងលើរួចមកហើយ ថាការរួបរួមខ្មែរមានជាធម្មជាតិ ព្រោះខ្មែរជាជនជាតិ នៃស្រុកមួយ មានអាយុរាប់ពាន់ឆ្នាំ។ តែដើម្បីឲជនជាតិខ្មែរ មានលក្ខណ: ជា ជនជាតិឧត្តម ដូចដី ដែលមានជីជាតិ ប្រជាពលរដ្ឋខ្មែរ ត្រូវមានការចេះដឹងក្នុងកំរិតខ្ពស់មួយ តាមការអប់រំជាតិ ត្រូវមានសីលធម៌ ជាប្រជាពលរដ្ឋថ្លៃថ្នូរ ត្រូវមានថាមពល ជាប្រជាជន ថាមវន្ត ហើយនឹង ត្រូវមាន ឆន្ទះ ក្នុងទស្សនវិស័យ ដល់ប្រជាជាតិ ព្រោះវត្ថុធាតុទាំងឡាយនេះ មិនអាចកើតឡើងដោយខ្លួនឯងបាននោះឡើយ៖ កើតជាខ្មែរ មិនមែនមានធម្មជាតិជា **សុជន**[33] មាន**សុធី**[34] នោះទេ។ បើខ្មែរមានគំនិតបែបនេះ គឺប្រាកដជាខ្មែរ មានការនិយមជាតិសាសន៍ ជាពុំខាន គឺទុកជាតិសាសន៍ខ្លួន ជាជាតិសាសន៍ឧត្តម ពីកំណើត។ ខ្មែរក្លាយជា សុជន មានសុធី ពីការអប់រំ ដោយខ្លួនឯងផង ពីសំណាក់ក្រសួងអប់រំជាតិផង។

## ១. ការរួបរួមជាតិ

ដូច្នេះ ការរួបរួមខ្មែរ ត្រូវធ្វើ តាម វិធីអប់រំ ឲខ្លួនក្លាយ ជាប្រជាពលរដ្ឋ **ចាប់ភព**[35] នូវ គុណសម្បត្តិ ដែលទើបតែបានរៀបរាប់ខាងលើនេះ ដើម្បី ឲការរួបរួម ជាធម្មតា ឲវាក្លាយទៅជាការរួបរួម ជាពលរដ្ឋ ឬ ការរួបរួម ដែលមានគុណភាព។ ការរួបរួម ដែលមានគុណភាព នេះ ដែលនាំ

[31] កុសិតបុគ្គល= មនុស្សខ្ជិលច្រអូស ; Idleness ; Paresse, Fainéant

[32] បុរេលក្ខខណ្ឌ= លក្ខខណ្ឌត្រូវមានពីដំបូង= Precondition ; Précondition។

[33] សុជន= មនុស្សល្អ ; Homme bon ; Good man។

[34] សុធី= ប្រជ្ញា, សេចក្តីឈ្លាសវៃ ; Intelligence, vivacité d’esprit ; Vivacity of mind។

[35] ចាប់ភព ; Incarnate ; s’incarner។

បង្កើតជា កម្លាំងជាតិ ដែលជា **កម្លាំងចូលផ្ចិត**[36] នៃកម្លាំងរួម របស់ ពលរដ្ឋម្នាក់ៗ ទោរទន់ចូលទៅទីកណ្តាល។ ទីកណ្តាល ជាការផ្តុំ នៃ **តម្លៃជាតិខ្មែរ**។ សួរថា អ្វីជា **គ្រិះ របស់ជាតិខ្មែរ** ? អ្វីជាតម្លៃ **របស់ជាតិខ្មែរ** ?

## ១.១. តម្លៃជាតិ

តម្លៃជាតិខ្មែរ ជាវត្ថុធាតុផ្លាស់ប្តូរ តាមការវិវត្តន៍ នៃសង្គមជាតិ ឧបមា តម្លៃជាតិក្នុងសម័យមហានគរខ្មែរ វាមិនដូចគ្នានឹង តម្លៃជាតិ សព្វថ្ងៃនេះឡើយ។ វត្ថុធាតុ មានៈ នយោបាយជាតិ, ការអប់រំជាតិ ដែលជាបច្ច័យ នៃការលូតលាស់ ចំរើននៃប្រជាជាតិ។ តម្លៃជាតិ វា ជាការផ្សំ នៃតម្លៃពលរដ្ឋ ហើយពលរដ្ឋហ្នឹងហើយ ដែលជាសិប្បករ នៃការលូតលាស់សង្គមជាតិ ព្រោះ **តួអង្គមនុស្ស**[37] ដែលជាជីវិតផ្នែកសម្ភារៈ ជាកំណើតដើម នៃជីវិតផ្នែកស្មារតី។ ហើយ ស្មារតីសង្គម គឺជា ទ្រឹស្តី នយោបាយ នឹង ច្បាប់, ទស្សនៈផ្នែកសាសនា, ផ្នែលទស្សនៈវិជ្ជា នឹង សីលធម៌សង្គម។ ប្រជាពលរដ្ឋ មានការចេះដឹង ទើបអាចមាន នយោបាយជាតិខ្ពង់ខ្ពស់បាន ហើយ ការចេះដឹង គឺកើតមក ពីការអប់រំ ដែលលើក កំរិតស្មារតី នៃពលរដ្ឋម្នាក់ ហើយ រួមគ្នាបង្កើតបាន ជាតម្លៃជាតិ។

នៅក្នុងសង្គមជាតិ គំនិត រួបរួម គឺជា ការរួបរួម រវាង **បុគ្គលនិយម**[38] ជាមួយនឹង **សនិទាននិយម**[39] ឬ តួអង្គមនុស្ស ជាមួយនឹង សីលធម៌ ដែលខ្លួនមាន គឺថា ការរួមរស់ រវាង **សិទ្ធិតួអង្គមនុស្ស**[40] ជាមួយនឹង **តួអង្គមនុស្សសង្គម**[41] តែនៅតែរក្សា ភាពខ្ពង់ខ្ពស់ នៃ សិទ្ធិតួអង្គមនុស្ស លើ តួអង្គមនុស្សង្គម ដែលជា មាតានៃទស្សនៈ នៃការប្រកាស សិទ្ធិមនុស្ស និង ពលរដ្ឋ។ ដូច្នេះ ភាពខ្ពស់ខ្ពស់នេះ គឺសំដៅទៅលើ **បុគ្គលនិយមជាសកល**[42] ដែលក្លាយទៅជា គ្រិះ នៃ សណ្តាប់ធ្នាប់ នយោបាយ និង សេរីភាព ដែលជាតួអង្គតែមួយគត់ អាចមានលទ្ធភាព ដឹកនាំ សណ្តាប់ធ្នាប់សង្គម។ គំនិត នៃ **សិទ្ធិបុគ្គលនិយម-សកលនិយម** គឺការរួបរួម ជាធម្មជាតិ រវាងវា ជាមួយនឹង **សកលនិយម នៃ វិចារញ្ញាណ** ដែលកំរិត ការការពារប្រយោជន៍ បុគ្គល។ ការរួមរួម ជាធម្មជាតិបែបនេះឯង ជាគ្រិះ នៃមនុស្សជាតិ ដែលទុក សិទ្ធិបុគ្គលនិយម-សកលនិយម ជាតម្លៃ នៃមនុស្សជាតិ ។ ដូច្នេះ តម្លៃជាតិខ្មែរ មិនត្រូវឃ្លាតឆ្ងាយ ពីតម្លៃ នៃមនុស្សជាតិ នោះឡើយ។

នៅក្នុង បរិបទខ្មែរ បច្ចុប្បន្ន ការអប់រំស្មារតីប្រជាពលរដ្ឋ គឺការចូលរួមប្រជាពលរដ្ឋទាំងអស់ក្នុងការប្រយុទ្ធកំទេច អំពើ អយុត្តិធម៌, ពុលរលួយ, អំណាចផ្តាច់ការ នឹង អាណានិគមកុម្មុយនិស្តយួន។ បើប្រជាពលរដ្ឋខ្មែរគ្មានស្មារតីទាំងនេះ ដែលជាគ្រោះថ្នាក់ដល់អាយុជីវិតជាតិ ខ្មែរ មិនអាចរក ការរួបរួមគ្នាបាននោះឡើយ។ ស្មារតីប្រាកដនិយមហ្នឹងហើយ ដែលជា តម្លៃជាតិ

---

[36] កម្លាំងចូលផ្ចិត= កម្លាំងទោរទន់ចូលទៅរកទីកណ្តាល ; Centripetal strength ; Force centripète។

[37] តួអង្គមនុស្ស= Being ; Etre។

[38] បុគ្គលនិយម= Individualisme។

[39] សនិទាននិយម= ការយល់ដឹង ដែលកើតមកពីវិចារញ្ញាណ ; Rationalisme។

[40] សិទ្ធិតួអង្គមនុស្ស= Etre de droit។

[41] តួអង្គមនុស្សសង្គម= Etre social។

[42] បុគ្គលនិយមជាសាកល= Individualisme universel។

ខ្មែរសព្វថ្ងៃ ជា **ភាគបែក**[43] រួម ប្រឈរមុខទល់នឹង គ្រោះថ្នាក់រួម។ ខ្មែរបច្ចុប្បន្ន មិនគ្រាន់តែ ត្រូវមាន តម្លៃពលរដ្ឋ ឲប្រសើរ តែប៉ុណ្ណោះ នោះឡើយ ដើម្បីរស់នៅក្បែរ ប្រជាជន ជិនខាងដែល មានជំនួនច្រើនលើសប្រជាជនខ្មែរ មាននយោបាយជាតិពិតប្រាកដ គឺត្រូវធ្វើយ៉ាងណា ឲតម្លៃ ខ្លួន ជាតួអង្គមនុស្ស ជាពលរដ្ឋ ឲមានតម្លៃឧត្តុងឧត្តម ទើបអាចជៀសវាង នូវអនុភាព នៃ ប្រទេសជិតខាងបាន។

## ១.២. គ្រិះ របស់ជាតិ

គ្រិះ នៃជាតិខ្មែរ ជា **ទម្រ អចិន្ត្រៃ** ជា **ឧបរិរចនាសម្ពន្ធ**[44] មាន៖ ប្រជាជាតិ, ប្រវត្តិសាស្ត្រជាតិ, ភាសា, សាសនា ហើយនឹង ទស្សនៈវិជ្ជា (ទស្សនៈវិជ្ជានៅក្នុងន័យ **គំនិតជាតិ**[45] គឺការពិចារណា អំពី កម្មផល មាននៅក្នុងពុទ្ធឪវាទ, សីលធម៌ មាននៅក្នុងច្បាប់ទាំងឡាយខ្មែរ, វប្បធម៌។ វត្ថុ ធាតុទាំងនេះ ជាវត្ថុធាតុ រឹង តាមធម្មតា មិនអាចប្រែប្រួលបាន។ តែយើងដឹងថា ប្រជាពលរដ្ឋ ខ្មែរ សព្វថ្ងៃ មាន **និម្មាណ**[46] ជាពហុជាតិសាសន៏៖ ខ្មែរ យួន ចិនចាម **មិលក្ខុ**[47] ហើយនឹង ជាតិ សាសន៏ផ្សេងទៀត។ ទោះបី ជាតិសាសន៏ខ្មែរ ជា ជាតិសាសន៏ ភាគច្រើនពិត តែលែងជា អង្គ ភាព លើសលុបជាងគេនោះឡើយ ព្រោះបើបូក ជាតិសាសន៏ យួនចិន នឹង ចាម ចូលគ្នា,ចំនួន ខ្មាន់ខ្មាប់ នៃការបូកនេះ ស្ទើរតែស្មើ ឬ ប្រហែលជាលើសផង លើចំនួន ជាតិសាសន៏ខ្មែរ ដែល ជាម្ចាស់ស្រុក។ ការពិតនេះ ចោទជាបញ្ហាដល់ ការចាត់ទុក គ្រិះរបស់ជាតិខ្មែរ ព្រោះជាតិសាសន៏ ដ៏ទៃទៀត គេមាន ប្រវត្តិសាស្ត្រ, ភាសា, សាសនា នឹង ទស្សនៈវិជ្ជា របស់គេផ្ទាល់ហើយជាពិសេស ដូចយ៉ាង យួន ចិន គេមាន បុព្វប្រទេស របស់គេ ជា នគរធំ មាន វប្បធម៌ខ្លែង ហើយថែមទាំង មាន ឥទ្ធពល ខ្លាំងក្លា មកលើ ស្រុកខ្មែរ ដែលជាប្រទេសទន់ខ្សោយបំផុត នាបច្ចុប្បន្នកាល នេះ។ ការណ៏នេះ នាំឲមានការប្រែប្រួលសំខាន់ដល់ ទស្សនៈ នៃឫសគល់សង្គមដើមខ្មែរ ដែល ជា សង្គមមាន សភាគភាព។ ការប្រែប្រួលនេះចោទជាបញ្ហា ដល់ការរក ការរួបរួមជាតិខ្មែរ ជា ធម្មជាតិផង ហើយនឹង ជាគុណភាពផង នៅក្នុងពេលសព្វថ្ងៃ ដែលស្រុកខ្មែរ កំពុងជួបប្រទះ នឹង វិបត្តិ សង្គម, នយោបាយ នឹង សីលធម៌។ ចំណោទនេះ ចោទសួរ ជាសំណួរថា ត្រូវធ្វើយ៉ាង ណា ដើម្បីឲ ពហុជាតិសាសន៏ អាចរួមរស់ ជាប្រជាពលរដ្ឋមួយ បាន ? យើងរកបានឧទាហរណ៏ជា ច្រើនមាននៅក្នុងពិភពលោកនេះដូចយ៉ាងមាននៅប្រទេសជិតខាងខ្មែរ៖ ម៉ាឡេស៊ី សង្ហបូរី ភូមិមា ថៃ និង សហរដ្ឋអាមេរិក ។ល។ តើ ឧទាហរណ៏ ទាំងនោះ វាអាចឆ្លើយនឹង បញ្ហាដែលមាន នៅស្រុកខ្មែរបានដែរឬទេ ?

មានចម្លើយបីយ៉ាង ដែលយើងលើកមកបង្ហាញ៖

**ចម្លើយទី១ :** អ្នកសង្គមសាស្ត្រ សង្កេតឃើញថា នៅក្នុងសង្គម ពហុជាតិសាសន៏ ឬ ពហុសហគម ន៏, ជាតិសាសន៏ណាមួយដែលខ្សោយ ច្រើនមានចំណង់ ចង់រស់នៅ តាមទំនាមទំលាប់ របស់ ខ្លួន ដែលនាំឲខ្លួន រំលឹកវា នូវ ស្មារតីរួម, ឆន្ទៈទួទៅ, ពលរដ្ឋ ហើយនឹង ច្បាប់ ដើមនៃសហគម

[43] ភាគបែក= denominator។
[44] ឧបរិរចនាសម្ពន្ធ= គោលរចនាសម្ពន្ធ ; Superstructure។
[45] គំនិតជាតិ= National philosophy ; Philosophie nationale។
[46] និម្មាណ= Structure។
[47] មិលក្ខុ= មនុស្សភ្នំ ; Highlander, montagnard។ ខ្មែរយើងហៅថា ខ្មែរលើ។

ន៍ របស់ខ្លួន។ ចំណង់នេះ ជា **កម្លាំងស្វ័យត្រាណ** មាននៅក្នុងធម្មជាតិ។ តែ សួរថា តើត្រូវធ្វើតាមវិធី ដែលអាចបញ្ចប់ ចលនាពីរប្រជល់គ្នា រវាងចលនា **សកលតាវូបនីយកម្ម**[48] ជាមួយនឹង ចលនា **ការប្រែរូប**[49] ដែលវានាំឲ្យខ្សោយ រូបរាងនៃជីវិតសង្គមនឹង នយោបាយ ចាស់ ដូចយ៉ាង តម្លៃសីលធម៌, តម្លៃពលរដ្ឋ។ ចំណង់នៃ ជាតិសាសន៍ខ្សោយ នេះ គឺជា ការបដិសេធ ច្រើនជាង ការអះអាង ហេតុនេះហើយ បានជានៅក្នុងគំនិត នៃការស្វាគមន៍ អ្នកដទៃ តែងតែក្លាយជា ការមិនព្រមរួមរស់នៅជាមួយ អ្នកដទៃ។ ក្នុងករណី ខ្មែរទន់ខ្សោយ ចំណង់ នូវការរក្សាទំនាមទំលាប់ វា ជា ការអះអាង ច្រើនជាង ការបដិសេធ ព្រោះចលនា សកលតាវូបណីយកម្មមកក្នុងស្រុកខ្មែរ ជា ចលនាធម្មជាតិផង ហើយនឹង ជា យុទ្ធសាស្រ្ត របស់អ្នកដទៃផង ជាពិសេសពីសំណាក់ យួនកុម្មុយនិស្ត ខ្លាំង ឆ្លៀតយក ចលនាធម្មជាតិជា **ភោគប្រយោជន៍**[50] ប្រើបំរើ មហិច្ឆាប្រវត្តិសាស្រ្ត របស់ខ្លួន ដើម្បីបង្កើត មហាវៀតណាម ឬ ឥណ្ឌូចិនថ្មី។ ឯចំណែកចិន ឆ្លៀត រកប្រយោជន៍ លើ ភាពទន់ខ្សោយខ្មែរ ដើម្បី យកទៅបំរើ សេដ្ឋកិច្ច ដូចជា ការផ្គត់ផ្គង់ សម្បត្តិធម្មជាតិខ្មែរ នឹង ការប្រើ ហត្ថពលខ្មែរ ជាកម្លាំងសត្វ។ តែទុព្វលភាព របស់ខ្មែរ គឺមានកើតឡើង ដោយសារខ្មែរខ្លួនឯងដែរ ដែលមានប្រវត្តិសាស្រ្ត ជាភស្តុតាង។ **ដំណាច់**[51]នៃប្រវត្តិសាស្រ្ត នៅមានរយៈពេលវែងអន្លាយ ចំពោះខ្មែរ បើយកស្ថានការណ៍ខ្មែរសព្វថ្ងៃមកពិនិត្យ ដូចយ៉ាង ការល្ងង់ខ្លៅ របស់ អ្នកដឹកនាំ នឹង អ្នកនយោបាយ, កម្រិតការចេះដឹង នៃប្រជាពលរដ្ឋ, ការវិចរិល នៃសីលធម៌ ហើយនឹង អវត្តមាន នូវទស្សនៈវិស័យ នៃអនាគត។ ទីកណ្តាល ដែលជាគ្រឹះខ្មែរ វាកាត់តែឃ្លាតឆ្ងាយ ពី **បរិមណ្ឌល**[52] ឧបមា ដូចជា ការខុសគ្នា រវាង ការរស់នៅ នៅក្នុងផ្ទះ នឹង ការរស់នៅ នៅតាមខ្ទល់ ដែលមាននៅក្នុងសុភាសិត នៃជនជាតិ Brésil។ គ្រឹះខ្មែរ សព្វថ្ងៃ កំពុងទទួល ឥទ្ធពលខ្លាំងក្លា ពីសំណាក់ បរិមណ្ឌល ដែលនាំឲបាត់បង់ កម្លាំងផ្ចិតផ្ចង់ ជាសង្គមជាតិ នាំហុចប្រយោជន៍ ដល់ សហគមន៍ យួន/ចិន ដែលជា **អង្គភាគ**[53] ប្រវញ្ចន៍រកតែចំណេញៗ។ សួរថា នៅក្នុង ល័ក្ខខ័ណ្ឌ បែបនេះ តើជនជាតិខ្មែរ អាចរួបរួម ជាមួយ ជនជាតិ យួន/ចិន ជាសង្គមជាតិបានដែរឬទេ ?

**ចម្លើយទី២ :** វាផ្ទុយនឹង ចម្លើយទី១ ព្រោះ ការបាត់បង់ នៃគ្រឹះជាតិខ្មែរ លុះត្រាតែជនជាតិខ្មែរសុខចិត្តបណ្តោយឲវាអាចកើតមានឡើងបាន។ ខ្មែរអាចនៅមាន មនោគតិ នៃការឆ្នៃប្រឌិតគឺទុកខ្លួន ជា ជនជាតិ **ទាន់សម័យ**[54] ព្រោះខ្មែរ កាត់តែបន្ថយបន្តិចម្តងៗ នៃជំនឿងប់ ទៅលើប្រវត្តិសាស្រ្តជាតិ ដែលឆ្នៃពីសំណាក់អ្នកដឹកនាំគ្រប់សម័យ សំរាប់ប្រយោជន៍គេ។ មួយវិញទៀតដោយសារ លក្ខណៈ ខ្មែរសម័យ នេះ នាំឲខ្មែរ រស់តាម ការរីកចំរើន នៃសង្គមជាតិ នៃមនុស្សលោក លែងគិតត្រឹមតែ **ការរស់នៅប្រសើរជាងមុន សំរាប់ថ្ងៃស្អែក**[55] តែខំស្វែងរក នូវ **របៀបរស់នៅថ្មី**[56] ក្នុងសម័យថ្មី។ ការស្វែងរកភាពប្រសើរជាងមុន ជា ចក្ខុវិស័យក្នុងរយៈពេលខ្លី រស់

---

[48] សកលតាវូបនីយកម្ម ; globalization។

[49] ការប្រែរូប= Privatization។

[50] ភោគប្រយោជន៍ ; Asset ; Atout។

[51] ដំណាច់= End ; Fin។

[52] បរិមណ្ឌល= មណ្ឌលនៅជុំវិញទីកណ្តាល ; Periphery។

[53] អង្គភាគ= សមាសភាព, ចំណែកមួយ ; Component ; Composant។

[54] ទាន់សម័យ= Postmodern។

[55] ការរស់នៅប្រសើរជាងមុន សំរាប់ថ្ងៃស្អែក= Live better tomorrow ; Vivre mieux demain។

[56] របៀបរស់នៅថ្មី= Vivre autrement ; live differently។

នៅក្នុងសង្គមបិទទ្វារ រស់នៅសំរាប់តែ «**អត្តា**» (moi) ឬ «**រស់នៅបែបនេះ**» (ça) ផ្ទុយពីការស្វែងរក របៀបរស់នៅថ្មី ជាការរស់នៅ ក្នុងចក្ខុវិស័យ នៃការស្វែងរកអនាគត សម័យថ្មី ក្នុងសង្គមចម្រុះ រស់នៅសំរាប់ «**យើង**» (nous)។ ចម្លើយទី២នេះ ជាចម្លើយ សុទ្ធិដ្ឋិនិយម ក្នុងគតិ នៃការទុកចិត្ត លើកម្លាំងជាតិខ្មែរ ក្នុងសង្គមចម្រុះ មានជាតិសាសន៍ដទៃ ជាអង្គភាគ ស្ម័គ្រ រួមរស់ជាសញ្ជាតិ តែមួយ។ សួរថា តើនៅក្នុងចម្លើយនេះ គ្រាន់តែជាឧត្តមគតិ ឬ ជាការពិត សំរាប់ខ្មែរ ?

**ចម្លើយទី៣** : ថិតនៅចន្លោះកណ្តាលនៃ ចម្លើយទី១ ដែលជា ចម្លើយ ទុទិដ្ឋិនិយម និង ទី២ ជាចម្លើយ សុទ្ធិដ្ឋិនិយម។ ចម្លើយទី៣ គឺយក យុត្តិធម៌ និង សមធម៌ ជាគោល នៃការរស់នៅ នៅក្នុងសង្គម។ ដើម្បីរួមរស់ជាមួយគ្នា នៅក្នុង ***វិវិធនៃរបបជីវិត***[57], អង្គភាគនិមួយៗ ត្រូវចាំបាច់គោរព ក្រមសីលធម៌ និង **សំណុំក្បួនសង្គម**[58] ដែលជា **លទ្ធិប្រជាធិបតេយ្យ តាមផ្លូវនីតិក្រម**[59] អ្វីដែលហៅថា លទ្ធិប្រជាធិបតេយ្យ តាមផ្លូវនីតិក្រម ? គឺថា វាមិនគ្រាន់តែនាំគ្នា គោរព ច្បាប់ជាផ្លូវការ គឺត្រូវមានៈ

- ការធានា នូវការគោរព សេរីភាព នៃជនម្នាក់ៗ និង សេរីភាពរួម ;
- ការណែនាំឲមាន ការពិភាក្សាជាសាធារណៈ នៃកិច្ចការសង្គម, កិច្ចការនយោបាយជាតិ ;
- ការបង្កើតឲមានក្រុមតំណាង នៃប្រយោជន៍ ក្រុម អង្គភាគ មាននៅក្នុងសង្គម ;
- ការបង្កើតច្បាប់ ជារដ្ឋធម្មនុញ្ញ នៃការអត់អាស្រ័យ ដល់គ្នាទៅវិញទៅមក។

ដើម្បីឲពលរដ្ឋម្នាក់ៗ មានស្មារតី មិនត្រឹមតែ រួមជាភាគមួយ នៅក្នុង សង្គម មាន វប្បធម៌ និង ប្រវត្តិសាស្ត្រ, ប៉ុន្តែត្រូវរួម ជាភាគមួយ ក្នុងសង្គមនយោបាយ ដែល គោរព គោលការណ៍នៃសេរីភាព, យុត្តិធម៌ និង ការអត់អាស្រ័យ ដែលមានចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ។

តែនៅក្នុងបរិបទខ្មែរ ចម្លើយនេះ អាចការពារ សហគ្គិភាព តែគ្មាន ការធានា ឲមានការទំនាក់ទំនង រវាង អង្គភាព នៃសង្គម នោះឡើយ។ ក្រុមនិមួយៗ មានសិទ្ធិ រស់នៅតាម របបជីវិតរៀងៗខ្លួន ស្របតាមច្បាប់ រដ្ឋធម្មនុញ្ញ។ ផ្លូវកសាងសង្គមជាតិ បែបនេះ ជាផ្លូវស្របតែប៉ុណ្ណោះ ឥតអាចជួបគ្នាបាន ដែលនាំឲសង្គមជាតិ មានវិវិធរាង ព្រោះអង្គភាគនិមួយៗ គ្រាន់តែរស់ ឲបានសុខជាមួយអ្នកដទៃតែប៉ុណ្ណោះ។

ក្នុងចម្លើយទាំង៣ យ៉ាងខាងលើនេះ ដែលនាំឲយើងធ្វើការពិនិត្យជាបន្តអំពីអ្នកបង្រួបបង្រួម។

## ២. ការបង្រួបបង្រួម

នៅក្នុងប្រទេស ដែលមាន ប្រជាពលរដ្ឋ ជា អធិបតី សំណួរថា ត្រូវបង្រួបបង្រួម ពលរដ្ឋ តាមវិធីណា ជាសំណួរ គ្មានន័យអ្វីនោះឡើយ ព្រោះថា ប្រជាពលរដ្ឋ ជាម្ចាស់ លើវាសនា របស់ខ្លួន ជា

[57] វិវិធនៃរបបជីវិត= Diverses modes de vie ; various lifestyles។
[58] សំណុំក្បួនសង្គម= Règles du jeu social ;
[59] លទ្ធិប្រជាធិបតេយ្យ តាមផ្លូវនីតិក្រម= Démocratie procédurale ; procedural democracy។

ម្ចាស់អំណាច ដូច្នេះ គ្មាននរណា មានឧត្តមភាព លើសប្រជាពលរដ្ឋ ដើម្បី បង្រួបបង្រួម ពលរដ្ឋ នោះឡើយ ផ្ទុយទៅវិញ មានតែប្រជាពលរដ្ឋ តែប៉ុណ្ណោះ ដែលជាអ្នកបង្រួបបង្រួម ពលរដ្ឋ ព្រោះខ្លួនជា អ្នករែក តម្លៃជាតិ ដែលខ្លួនជាអ្នកបង្កើត ដោយខ្លួនឯង ដើម្បីប្រយោជន៍ខ្លួនឯង។

តែគេអាចសួរជាសំណួរថា ប្រជាពលរដ្ឋត្រូវការអ្នកដឹកនាំ ទើបសង្គមអាចមានសណ្តាប់ធ្នាប់បាន ពុំនោះសោធ គឺច្បាស់ជាមាន អនាធិបតេយ្យ ក្នុងសង្គមជាតិ ជាពុំខាន។ ពិតប្រាកដណាស់ថា សង្គមជាតិនិមួយៗ ត្រូវចាំបាច់មាន អ្នកដឹកនាំជាតិ តែក្នុងប្រទេសណា ដែលមានប្រជាពលរដ្ឋ ជាធិបតី អ្នកដឹងនាំនេះ គឺគ្រាន់តែជាតំណាង របស់ប្រជាពលរដ្ឋ ដែលប្រជាពលរដ្ឋ ជ្រើសរើសតាំងឡើង ដើម្បីធ្វើបំរើ ឆន្ទះខ្លួន ស្របតាមច្បាប់ប្រជាពលរដ្ឋ ដោយប្រជាពលរដ្ឋ និងដើម្បី ប្រជាពលរដ្ឋ។ សួរថា នៅពេលដែលប្រជាពលរដ្ឋជ្រើសរើសតំណាងខ្លួនបានហើយ តើត្រូវព្យួរអំណាចប្រជាពលរដ្ឋ ជាបណ្តោះអាសន្នដើម្បីប្រគល់ឲអ្នកតំណាង យកទៅប្រតិបត្តិ។ ក្នុងចំណុចនេះ មានទស្សនៈពីរខុសគ្នា៖

**ទី១** ដែលគេឃើញមានក្នុងទ្រឹស្តី បដិវត្ត បារាំង ដែលប្រគល់ **សណ្តាប់ធ្នាប់នយោបាយ**[60] ទៅឲ **អំណាច បដិដ្ឋាភាពនៃប្រជាពលរដ្ឋ**[61] ដែលជាអ្នកកំរិត អំណាចប្រជាពលរដ្ឋ នៅក្នុងកាលៈទេសៈពិសេសណាមួយ ដែលចាំបាច់ត្រូវព្យួរមួយរយៈពេល នៃអំណាចប្រជាពលរដ្ឋ ដើម្បីឲក្រុមតំណាងប្រជាពលរដ្ឋ ដឹកនាំ សណ្តាប់ធ្នាប់នយោបាយ ឧបមាដូចជា អំណាចផ្តាច់ការ នៃវណ្ណៈពលជីព ជាអ្នកដឹកនាំនយោបាយ ដើម្បីកសាង សង្គមគ្មានវណ្ណៈ ឬ សង្គមកុម្មុយនិស្ត ដែលទុកជាឆន្ទៈជាតិ ឬ ប្រយោជន៍ជាតិ។ ទស្សនៈ នេះ មានប្រភពចេញពីទ្រឹស្តី លោក Karl Marx។

**ទី២** ដែលគេឃើញមានក្នុង លទ្ធិប្រជាធិបតេយ្យ អាមេរិកាំង ដែលទុកអធិបតេយ្យភាពប្រជាពលរដ្ឋ ជា **តម្លៃមជ្ឈន្តិកៈ**[62] ដែលជាតម្លៃ មាននៅក្នុងទឹកចិត្តពលរដ្ឋម្នាក់ៗ កើតចេញពីទំលាប់ក្នុងការប្រព្រឹត្តិ ល្អ ឬ អាក្រក់។ អធិបតេយ្យប្រជាពលរដ្ឋ បែបនេះ មានធាតុបរិសុទ្ធ នៅក្នុងអំណាចនយោបាយ ដែលទុកប្រជាពលរដ្ឋ ក្លាយទៅជាខ្លួនតែមួយនៃប្រជាជាតិ ជាម្ចាស់អំណាច ឥតអាចព្យួរ ទោះបីក្នុងរយៈពេលខ្លី ក៏មិនបានដែរ។ ខុសពី ប្រទេសអ៊ឺរ៉ុប ដែលនៅមានធាតុលាយខ្លះ កើតក្រោមទម្ងន់ ប្រវត្តិសាស្ត្រ នៃវណ្ណៈអភិជន ជាមួយ ប្រវត្តិសាស្ត្រ នៃបដិវត្តិ ដើម្បីរក សមតាភាព ក្នុងសណ្តាប់ធ្នាប់នយោបាយ។

ទស្សនៈទី២ នេះ ដែលជាគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ នៃបស្ចឹមប្រទេសបច្ចុប្បន្ន ជួនកាលមានរាងទៅតាមសេចក្តីត្រូវការរបស់ប្រទេសនិមួយៗ ជាលទ្ធិប្រជាធិបតេយ្យប្រព័ន្ធប្រធានាធិបតី ជួនកាលជាលទ្ធិប្រជាធិបេតយ្យ អាស្រ័យ សភា ជួនកាលជាលទ្ធិប្រជាធិបតេយ្យដោយចំពោះ។ រីឯទស្សនៈទី១ វិញ នាំបង្កើត ជាលទ្ធិប្រជាធិបតេយ្យ បែបសង្គមនិយម ឬ ប្រជាមមានិត ដែលជាមាតា នៃរបបកុម្មុយនិស្ត ប្រើអំណាចផ្តាច់ការ ដើម្បីកសាងសង្គមគ្មានវណ្ណៈ ដែលជាការស្រម័យ ជាមរណា ច្រើនជាងការពិត។

យើងគួរលើកចំណុច ស្តីអំពី ពាក្យថា «ឆន្ទៈជាតិ»ឬ «ប្រយោជន៍ជាតិ» មកពិនិត្យ ដើម្បីធ្វើការប្រុងប្រយ័ត្ន នៃ ការរំលោភ ពីសំណាក់ អ្នកដឹកនាំផ្តាច់ការ ធ្វើការបង្រួបបង្រួម ដោយបង្ខំ

---

[60] សណ្តាប់ធ្នាប់នយោបាយ= Ordre politique។

[61] បដិដ្ឋាភាពនៃប្រជាពលរដ្ឋ= អំណាចសភាបញ្ញត្តច្បាប់ ; Pouvoir constituant du peuple។

[62] តម្លៃមជ្ឈន្តិកៈ= Valeur intrinsèque។

ដើម្បីបំរើប្រយោជន៍ជាតិ ដែលខ្លួន ជាអ្នកសំរេច តែបន្ទាប់ ប្រយោជន៍រួម ដែលប្រជាពលរដ្ឋចង់បាន។ ឧទាហរណ៍ នៅស្រុកខ្មែរសព្វថ្ងៃ គណបក្ស កាន់អំណាច គេធ្វើនយោបាយបង្រួបង្រួមជាតិ យកគណបក្សសង្គ្រោះជាតិជាដៃគូ ដោយប្រើពាក្យ រក្សាសន្តិភាព ថាជា ប្រយោជន៍ជាតិ តែក្នុងប្រយោជន៍ជាតិនេះ វាគ្មានឃើញមានសោះ ប្រយោជន៍រួម របស់ប្រជាពលរដ្ឋ គឺ សុខុមាលភាព សុវត្ថិភាព និង ភាពប្រយោល នៃអនាគតដ៏ល្អមួយ សំរាប់ ប្រជាពលរដ្ឋ។

នៅក្នុងបរិបទខ្មែរសព្វថ្ងៃ ដែលមាន លទ្ធិប្រជាធិបតេយ្យ បោះឆ្នោត ឡប់ឡែ **ឡាំសាំ**[63] ដែលជាកូន របស់លទ្ធិកុម្មុយនិស្ត ជារបបដឹងនាំ យកការចរចារ រវាងគណបក្សនយោបាយ មកធ្វើជា ការបង្រួបបង្រួមគ្នា បំពានលើច្បាប់ ទុកជាប្រយោជន៍ជាតិ។ ការបង្រួបបង្រួមគ្នានេះ ជាការបោកប្រាស ធ្វើឡើង ដើម្បីតែសេចក្តីសុខរបស់ អ្នកដឹងនាំតែប៉ុណ្ណោះ។ ជាពិសេស អ្នកខ្លាំងដែលជាអ្នកឈ្នះតាមអំពើទុច្ចរិត ជាអ្នកបង្រួបបង្រួម អ្នកខ្សោយ ដែលជាអ្នកចាញ់ល្វីល្វើ សុំសុខ បំពានលើឆន្ទៈរាស្ត្រ ; យករាស្ត្រ ធ្វើជាក្របី សំរាប់ជិះ ឆ្លងភក់ ដល់ត្រើយ សោយគូទ នាំគ្នារស់ដូចស្វា ក្នុងទ្រុងលាបព៌ណមាស លើដៃករនាំងគុក ធ្វើឬកជាអាមាត្យអត្តខាត់ប្រាជ្ញា។

ឧទាហរណ៍មានច្រើន ក្នុងអតិតកាល ដូចយ៉ាង នៅក្នុងរបបរាជានិយមផ្តាច់ការខ្មែរ ក្រុមវាំងគេជាអ្នកបង្រួបបង្រួមរាស្ត្រខ្មែរ ដើម្បីការពារព្រះមហាក្សត្រ ដែលគេទុកជាប្រយោជន៍ជាតិ គឺថា អត់ស្តេច គឺអត់ជាតិ ; ក្នុងសម័យសង្គមរាស្ត្រនិយម ឬ សីហនុនិយម ក្រុមវាំងដដែល គេជាអ្នកបង្រួបបង្រួមជាតិ ដើម្បីការពារបុគ្គលសីហនុ ដែលគេទុកជាប្រយោជន៍ជាតិ គឺថា អត់សីហនុ គឺ ជាតិមានកលិយុគ ; ក្នុងសម័យខ្មែរក្រហម អង្គការលើ ជាអ្នកបង្រួបបង្រួមជាតិដើម្បីការពារបដិវត្តន៍ គឺថា អត់បក្សបដិវត្តន៍ គឺ មានវណ្ណៈជិះជាន់ ; ក្នុងសម័យ យួនកុម្មុយនិស្ត ត្រួតត្រស្រុក បក្សកុម្មុយនិស្តយួន គេជាអ្នកបង្រួបបង្រួមខ្មែរ ដើម្បីការពារ លទ្ធិកុម្មុយនិស្ត គឺថា អត់បក្សកុម្មុយនិស្តយួន គឺខ្មែរសម្លាប់ខ្មែរគ្នាឯង ; ក្នុងសម័យបច្ចុប្បន្ន គណបក្សប្រជាជន គេជាអ្នកបង្រួបបង្រួមខ្មែរ ដើម្បីការពារប្រយោជន៍យួន គឺថា អត់យួន គឺ គណបក្សប្រជាជនស្លាប់។ សួរថា តើអ្នកស្នេហាជាតិខ្មែរ អាចបង្រួបបង្រួមខ្មែរ បានដែរឬទេ ?

នៅក្នុងចំណុច **ខ្មែរអ្នកស្នេហាជាតិ** នេះទៀត គួរយើង ឲអត្ថន័យឲច្បាស់លាស់ ដើម្បីរកធាតុពិតរបស់ពាក្យ «ស្នេហាជាតិ»។ សួរជាសំណួរថា យក យួន, ស្តេច ។ល។ ជាសត្រូវ ជាសញ្ញាល័ក នៃសេចក្តីស្នេហាជាតិ ឬ ? ខ្មែរក្រហម ច្បាំងនឹង យួន មិនមានន័យថា ជាអ្នកស្នេហាជាតិ នោះទេ ព្រោះ លោក ប៉ុល-ពត គាត់ **រានទី**[64]នឹង យួន ដើម្បីការពារអំណាចរបស់គាត់តែប៉ុណ្ណោះ ; បើគាត់ស្នេហាជាតិពិត គឺគាត់មិនធ្វើនយោបាយ សម្លាប់មហាជនខ្មែរ ដែលជាញាតិផ្ទាល់របស់គាត់នោះឡើយ។ លោក សម-រង្ស៊ី និង កែម-សុខា បើគាត់ជាអ្នកស្នេហាជាតិពិត គាត់មិនព្រមដាច់ខាតចរចារជាមួយ លោក ហ៊ុន-សែន ដែលខ្មែរភាគច្រើនដាច់ខាត ចាត់ទុកជាក់លាក់ថា ជាសត្រូវរបស់ជាតិខ្មែរ។ ស្នេហាជាតិ ជាអាទិ គឺជា អារគារ នៃ **ប្រជាជាតិ**[65] ហើយប្រជាជាតិមិនមែនជា ជាតិសាសន៍ ដែល ជា **ក្រុមជាតិពិន្ទុសាស្ត្រ**[66] ជា **ភាសាវិទ្យា**[67] ឬ ជា **សាសនា** នៃ

[63] ឡាំសាំ= Vulgaire។ ឧទាហរណ៍ : នាំគ្នាឆ្នាំលទ្ធផលបោះឆ្នោត ដើម្បីចែកប្រយោជន៍គ្នា។

[64] រានទី= ប្រយុទ្ធតទល់ ; Affronter។

[65] ប្រជាជាតិ= Nation។

[66] ក្រុមជាតិពិន្ទុសាស្ត្រ= Groupes ethnographiques។

[67] ភាសាវិទ្យា= Linguistiques។

ប្រជាជននិមួយៗតែប៉ុណ្ណោះឡើយ។ ខ្លឹមនៃប្រជាជាតិ គឺជា ការរួមរស់ជាមួយគ្នា នៃបុគ្គលទាំងអស់ ដែល មាន របបជីវិត ដូចគ្នាច្រើនណាស់ ហើយ ភ្លេចអស់ ភាពដូចគ្នានេះ ព្រោះវាបានរលាយចូលគ្នាតែមួយទៅហើយ ឧបមា ខ្មែរគ្រប់សម័យ វាក្លាយជាខ្មែរតែមួយនោះឯង។ ប្រជាជាតិ ជួនកើតមក ពីការបង្រួបបង្រួម ដោយអំណាច ជួនកើតមក ពីឆន្ទៈរួម នៃក្រុមប្រជាជននិមួយៗ។ ក្នុងប្រវត្តិសាស្ត្រខ្មែរ ការប្រកាសបង្កើតប្រជាជាតិខ្មែរ មាននៅក្នុងរជ្ជកាលព្រះបាទហ៊ុន-ទៀន (ដើមស.វ.ទី៣) ជាអ្នកឈ្នះសង្គ្រាម លើ ព្រះនាង លីវ-យី បន្ទាប់មកព្រះអង្គ បង្រួបបង្រួម ជាតិព័ន្ធទាំងឡាយ ឲ្យរួមរស់នៅក្នុងប្រជាជាតិតែមួយ មានឈ្មោះថាអាណាចក្រភ្នំ ឬ ហ្វូណន។ ក្រោយមកទៀត គឺមាននៅក្នុង រជ្ជកាល ព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៥០) ជាអ្នកឈ្នះសង្គ្រាម ប្រកាសបង្កើត ប្រជាជាតិថ្មីមួយ ដែលមានឈ្មោះថា កម្ពុជា គឺបង្រួបបង្រួមជាថ្មីឡើងវិញ នូវប្រជាជន ចេនឡា (ចេនឡាដីគោក) ជាមួយ ប្រជាជន ចេនឡា ទឹក (ហ្វូណន) ដូច្នេះ គេអាចសន្និដ្ឋានបានថា ប្រជាជាតិសម័យ ជាលទ្ធផល ប្រវត្តិសាស្ត្រ នៃ ការប្រមូល នូវការណ៍ មួយចំនួន ដែលមានគោលដៅដូចគ្នា បង្កើតបានជា របបរស់នៅរួមគ្នា។ ប្រជាជាតិខ្មែរ កើតមកពីការបង្រួបបង្រួម ដោយអំណាចយោធា នៃរាជវង្ស នៃព្រះមហាក្សត្រ ហេតុនេះឯងបានជាខ្មែរមានទំលាប់ យកសម័យមហានគរ ដែលជាសម័យ **ពិនាល័យ**[68] មកធ្វើជា បេះដូង នៃប្រជាជាតិខ្មែរ។ គំនិតនេះ វាផ្ដិតជាប់នៅក្នុងសតិខ្មែរ រហូតមកដល់សព្វថ្ងៃ ព្រោះការវិវត្តន៍ នៃសិទ្ធិរាស្ត្រ វាស្ទើរតែឥតមានសោះតែម្ដងនៅស្រុកខ្មែរ។ សិទ្ធិរាស្ត្រនេះឯង ដែលជាខ្លឹម នៃពាក្យ **ជាតិភូមិ**[69] និង **ពលរដ្ឋ** ; ដែលគេអាចប្រដូចបានថា ទី១ ទុកដូចជា អង្គកាយ, ទី២ ទុកដូច ជាបេះដូង។ ក្នុងទស្សនៈ សិទ្ធិពលរដ្ឋនេះ អាចឲគេធ្វើអនុមានបានថា ប្រជាជាតិអាចមានដោយមិនចាំបាច់ មានរាជវង្ស មហាក្សត្រជា ខ្លឹម។ ក្នុង ទស្សនៈនេះទៀត គេយក សិទ្ធិជាតិ ដែលជាសិទ្ធិប្រជាពលរដ្ឋ មកជំនួស សិទ្ធិ ព្រះមហាក្សត្រ ឬ វណ្ណៈ នៃអ្នកដឹកនាំ។ **តើអ្វីជាសិទ្ធិជាតិ** ?

នៅក្នុងចំណុចនេះ មានទស្សនៈមួយយល់ឃើញថា សិទ្ធិជាតិ គឺ ជា សិទ្ធិ នៃពូជសាសន៍ ដែលផ្សំគ្នា រវាង សិទ្ធិ និង ផម្ពានុរូប។ ទស្សនៈនេះ វាបង្កើត ជា **សិទ្ធិ ជាដើមកំណើត**[70] ដូចគ្នានឹង សិទ្ធិស្ដេចនោះឯង ដែលច្រើនកើតឡើងពី អំពើហឹង្សា រួច រក្សាវា ដើម្បីការពារប្រយោជន៍វណ្ណៈឬពូជសាសន៍។ ពាក្យ ពូជសាសន៍ មាន **ដើមកំណើតចេញពី សត្វសាស្ត្រ នៃមនុស្សជាតិ**[71] ដែលជាដើមកំណើត កើតមុន ដើមកំណើត នៃវប្បធម៌, នៃអារ្យធម៌, នៃភាសា។

តែគេដឹងថា ដើមកំណើតដំបូងនេះ មានកើត មានស្លាប់ នៅក្នុង ប្រវត្តិសាស្ត្រ នៃមនុស្សជាតិ។ គេដឹងថា ប្រវត្តិសាស្ត្រ មនុស្សលោក ខុសផ្លែកពី ប្រវត្តិសាស្ត្រ សត្វសាស្ត្រ ព្រោះ នៅក្នុងប្រវត្តិសាស្ត្រ មនុស្សលោក មានស្ដីអំពី វិច្ចារណញ្ញាណ, យុត្តិធម៌, សោភ័ណភាព, លោកកិយសច្ចៈ ដែលមនុស្សលោកម្នាក់ៗមានដូចគ្នា។ ចំណុចទាំងឡាយនេះឯងហើយ ដែលជា គ្រឿងយន្ត នៃវឌ្ឍនភាព នៃសង្គមមនុស្សលោក ខុសពី សត្វសាស្ត្រ។

---

68 ពិនាល័យ= Paradis des guerriers។

69 ជាតិភូមិ= មាតុភូមិ ; Homeland ; Patrie។

70 សិទ្ធិ ជាដើមកំណើត= Droit patrimonial។

71 ដើមកំណើតចេញពី សត្វសាស្ត្រ នៃមនុស្សជាតិ=Les origines zoologiques de l’humanité។

បើនិយាយអំពី ពូជសាសន៍ ត្រូវចាំបាច់ និយាយអំពីភាសា។ ភាសាជាកត្តា បង្រួបបង្រួមជាតិដែរឬទេ ? ឧទាហរណ៍ នៅ សហរដ្ឋអាមេរិក ជាតិសាសន៍ ជាច្រើន និយាយភាសាតែមួយ រួមគ្នាបង្កើតបាន ជាប្រជាជាតិមួយខ្លាំងពូកែ។ ប៉ុន្តែ បើគ្រាន់តែនិយាយ ភាសាដូចគ្នា តែគ្មានសោះឆន្ទៈរួម ក៏ពុំអាចបង្កើតបានជាប្រជាជាតិបាននោះដែរ។ តែភាសា ក៏មិនមែន សំដៅតែលើជាតិសាសន៍ ព្រោះភាសា ជា និម្មិតកម្ម ប្រវត្តិសាស្ត្រ ដែលទាក់ទងតិចតួចណាស់នឹងពូជសាសន៍។ ភាសា អាចដូរទៅតាម តម្រូវការ នៃការរស់នៅរបស់មនុស្សលោក។ ឧទាហរណ៍ បើខ្មែរចង់រស់ស្រួលនៅ សហរដ្ឋអាមេរិក ត្រូវចាំបាច់រៀនភាសាអង់គ្លេស។

រីឯ សាសនា វិញ ក៏មិនអាចយកជា មូលដ្ឋានមាំទាំ សំរាប់ ទុកជាខ្លឹម នៃប្រជាជាតិបាននោះដែរ ព្រោះសាសនានិមួយៗ វាជា ជំនឿសកល។ ខ្មែរកាន់ពុទ្ធសាសនា ក៏ដូច ជា ជនជាតិដ៏ទៃទៀតដែរ។ គេអាចទុកសាសនា ជា អត្តសញ្ញាណ របស់ប្រជាជាតិ បានដែរ ដូចយ៉ាងមាននៅក្នុងបាវចនា នៃប្រជាជាតិខ្មែរ តែអត្តសញ្ញាណនេះ មាន លក្ខណៈ ជាក្រមសីលធម៌ សំរាប់បុគ្គលដែលជាសមាជិករបស់ប្រជាជាតិតែប៉ុណ្ណោះ។ សាសនា មិនអាចជាកត្តា បង្រួបបង្រួមជាតិបាននោះដែរ ព្រោះប្រយោជន៍សាសនា វាខុសគ្នានឹង ប្រយោជន៍រួម និង ប្រយោជន៍ជាតិ ព្រោះប្រយោជន៍សាសនា ជាប្រយោជន៍បុគ្គល មានលក្ខណៈជាប្រយោជន៍ អាថិកំបាំង ដែលបុគ្គលម្នាក់ប្រថ្នារក។ រីឯ ប្រយោជន៍រួម និង ប្រយោជន៍ជាតិ វិញ ជា ការសំដែង ចេញមុខ ជាសាធារណៈ។ គេពុំអាចប្រកាស ការពារប្រយោជន៍ជាតិ ឬ រួម នៅក្នុងចិត្តបាននោះឡើយ។ ឧទាហរណ៍៖ *ខ្ញុំស្រឡាញ់ជាតិ តែកុំប្រាប់អ្នកណាឲដឹងសោះ*។ គិតបែបនេះ ជា គំនិត គួរឲអស់សំណើចណាស់។

**អ្វីជាប្រជាជាតិ ?** ជា **ព្រលឹង** និង ជា **គោលការណ៍គំនិត**។ របស់ពីរ រួមគ្នាជាមួយ ; ទី១ គឺនៅក្នុង អតីតកាល ; ទី២ គឺនៅក្នុង បច្ចុប្បន្នកាល។ ទី១ ជា **ភោគរួម**[72] នៃ **អច្ច័យទាន**[73] ដ៏សម្បូណ៍ នៃអនុស្សាវរីយន៍ ; ទី២ ជា **ការយល់ព្រមគ្នា** មាននៅក្នុងបច្ចុប្បន្ន ដូចយ៉ាង ចំណង់ចង់រស់ជាមួយគ្នា, ឆន្ទៈរួម អះអាងបន្ត ជាម្ចាស់ នៃមរតករួម ដែលបុគ្គលម្នាក់បានទទួល។ របស់ទាំងពីរនេះហើយ ជា មូលធនសង្គម ដែលគំនិតជាតិ យកជាមូលដ្ឋាន។ មាន កិត្តិគុណរួម ក្នុងអតីតកាល ; មាន ឆន្ទៈរួម ក្នុងបច្ចុប្បន្នកាល ; បានធ្វើអ្វីមួយដ៏សំខាន់ ជាមួយគ្នា ហើយចង់បន្តកសាងជាមួយគ្នា នូវអ្វីសំខាន់មួយទៀត, នេះហើយ ដែលជា ល័ក្ខខ័ណ្ឌ ជាសារវន្តដើម្បី ជាប្រជាពលរដ្ឋ នៃប្រជាជាតិ។ មានចំរៀងមួយ របស់ជនជាតិ Sparte ថា៖ Nous sommes ce que vous fûtes ; nous serons ce que vous êtes។ «យើងជានរណាម្នាក់ ដូចអ្នកជាជននេះ ; យើងនឹងទៅជានរណាម្នាក់ ដូចអ្នកកំពុងជាជននេះ»។ ន័យរបស់ចំរៀងនេះ គឺ ជា ការសង្ខេបមួយ នូវគោលការណ៍ នៃ ប្រជាជាតិ។ ដូច្នេះ ស្នេហាជាតិ មិនមែនគ្រាន់តែជា អំពើ, សំដី តែត្រូវមានទឹកចិត្ត ឆន្ទៈរួម ដែលបានរៀបរាប់ខាងលើនេះ។

**សេចក្ដីស្នេហាជាតិ ជាអ្វី ?** សព្វថ្ងៃនេះ អ្នកជាតិនិយមខ្មែរ យក ពាក្យ «ប្រឆាំងយួន» ជាលក្ខណវិនិច្ឆ័យ នៃ សេចក្ដីស្នេហាជាតិ គឺថា ជាអាទិ បើស្រឡាញ់ខ្មែរ ត្រូវស្អប់យួន ព្រោះជាសត្រូវតពូជ។ ដូច្នេះ គេអាចបង្រួបបង្រួមខ្មែរបាន ដោយយកលក្ខណវិនិច្ឆ័យនេះ ជាគោល។ វត្ថុធាតុនេះ ឈរលើ ទោសៈរាប់ពាន់ឆ្នាំ មានភស្តុតាង ក្នុងប្រវត្តិសាស្ត្រ ខ្មែរ/យួន, មានរូបិយជាក់ស្តែងនៅស្រុកខ្មែរសព្វថ្ងៃ គឺការហូរចូលជនជាតិយួន មកក្នុងកម្ពុជា រាប់លាននាក់, ដូច្នេះកំហឹងអ្នក

[72] ភោគរួម= Possession en commun។

[73] អច្ច័យទាន= អំណោយដោយលិខិតបណ្ដាំនៃបុគ្គលម្នាក់មុនស្លាប់ ; Legs។

ជាតិនិយមខ្មែរនេះ ជាកំហឹងត្រឹមត្រូវ តែជាកំហឹង ក្នុងលក្ខណៈ**សន្តាបចិត្ត**[74]នាំបង្កើតការអស់សង្ឃឹម ច្រើនជាង សេចក្តីសង្ឃឹម ព្រោះកំហឹង តាមធម្មជាតិវា ជាកម្លាំងបំផ្លាញ។ តែ កំហឹងក៏អាចជា ការដាស់តឿនចិត្ត ព្រោះវាមានធាតុជា កម្លាំងរំពើក មិនព្រមចុះចាញ់ មិនរំសាយនៅតែ ប្រកែកតវ៉ា រកយុត្តិធម៌ ជានិច្ច នៅចំពោះមុខ កម្លាំង សង្កត់សង្កិនៈ សេចក្តីស្វិតស្វាញ, សេចក្តីរឹងរូស, សេចក្តីក្លាហាន នៅឋិតថេរ ជានិច្ច បង្កើតបាន ជាកម្លាំងតស៊ូ មិនអាចទុបទល់បាន ប្រកបដោយអានុភាព មិនអាចសាបសូន្យ ហេតុនេះឯង បានជាគេទុកកំហឹង ប្រឆាំងនឹង កម្លាំង និគ្រោះ, ការឈ្លានពានពីសំណាក់បរទេស ជា គុណធម៌ នៃ កម្លាំងតស៊ូ មួយ សំរាប់ការពារខ្លួនដោយខ្លួនឯង។ ក្នុងធាតុទី២ របស់កំហឹងនេះឯង ដែលអាចយកមកធ្វើគោលនៃការបង្រួបបង្រួមខ្មែរបានជា ការការពារជាតិដោយខ្លួនឯង ខុសពីធម្មជាតិរបស់កំហឹង ជាកំម្លាំងបំផ្លាញ ដែលអាចទាញទៅរក ការប្រកាន់ជាតិសាសន៍និយម។ ទី១ ជា កម្លាំង អវិជ្ជមាន រីឯទី២វិញ ជាកម្លាំង វិជ្ជមាន សំរាប់ការពារជាតិខ្មែរ ដោយខ្មែរខ្លួនឯង។

## សេចក្តីសន្និដ្ឋាន

រួបរួមជាតិ ឬ បង្រួបបង្រួមជាតិ ជា មូលដ្ឋាន នៃប្រជាជាតិ។ ត្រូវចាំបាច់មានការរួបរួមជាតិជាអាទិ ទើបអាចមានការបង្រួបបង្រួមជាតិបាន។ ដូចបានជំរាបខាងលើរួចមកហើយថា រួបរួមជាតិ ជាដីមានជីជាតិ រីឯ បង្រួបបង្រួមជាតិ ការដាំបន្លែ ដូច្នេះត្រូវ ចេះជ្រើស គ្រាប់ពូជ, រដូវ, បរិស្ថាន ទើបអាចមានផលបានល្អ។ អ្នកជ្រើសរើស ត្រូវមាន ការចេះដឹង ទើបអាច ស្គាល់គ្រាប់ពូជល្អ ស្គាល់រដូវ ស្គាល់បរិស្ថាន ដើម្បីដាំឲបានផលល្អ។

បង្រួបបង្រួមជាតិ ជាអំពើផង ជាទឹកចិត្តផង។ ទឹកចិត្តមាននៅក្នុងការរួបរួមជាតិ ដែលមានមូលដ្ឋាន ព្រលឹងជាតិ និង គោលការណ៍គំនិតជាតិ ដែលមានរៀបរាប់ខាងលើ។ អំពើ ត្រូវមានំ ធ្យោបាយ ដែលមាននៅក្នុងការរួបរួមជាតិ និង អ្នកដឹកនាំប្រកបដោយ សិលធម៌។ រីឯវិធី គឺ គឺ យកច្បាប់ជា មូលដ្ឋាន ដែលជាច្បាប់ប្រជាពលរដ្ឋ ដោយប្រជាពលរដ្ឋ ដើម្បី ប្រជាពលរដ្ឋ។ បើគ្មានច្បាប់នេះទេ ប្រជាពលរដ្ឋខ្លួនឯង ត្រូវនាំគ្នាបង្កើត ដោយប្រើអំណាចប្រជាពលរដ្ឋ តាមមធ្យោបាយគ្រប់គ្រាន់ដែលខ្លួនមាន ដើម្បីបង្កើតច្បាប់នេះឲមានជាដាច់ខាត។ រួមសេចក្តីមក ការបង្រួបបង្រួមជាតិ គឺគ្មានអ្វីក្រៅពីការអនុវត្តន៏ច្បាប់ជាតិ អន្តរជាតិ ធម្មជាតិ ឲបានពិតប្រាកដនោះឡើយ ដែលមានខ្លឹមប្រជាជាតិ ជាគោល និង ជាទិសដៅ។ បើខ្មែរ គ្មានការរួបរួមជាតិ គ្មានការបង្រួបបង្រួមជាតិ នៅក្នុងការលះទេសៈខ្មែរបច្ចុប្បន្ននេះ គឺច្បាស់ប្រជាជាតិខ្មែរ រលាយជាពុំខាន ដូច្នេះ ការរួបរួមជាតិ ជាអំពើរតស៊ូរ ដើម្បី ឲព្រលឹងជាតិខ្មែរ រស់ឡើងវិញ និង គោលគំនិតជាតិ ដើម្បី អភិវឌ្ឍន៍សង្គមជាតិ ដើម្បីប្រជាពលរដ្ឋ។

**-ចប់-**

[74] សន្តាបចិត្ត= ខកចិត្ត ; Frustration។